# តើខ្ញុំមានសិទ្ធិអ្វីខ្លះ?

អ្នកមានសិទ្ធិដើម្បីដឹងពីព័ត៌មានសុខភាពអ្វីខ្លះដែលគេកាន់កាប់អំពីអ្នក របៀបយ៉ាងណា និងហេតុអ្វីបានជាគេប្រមូលវា ហើយតើគេយកវាប្រើប្រាស់សម្រាប់គោលបំណងអ្វីខ្លះ។

អ្នកអាចស្នើសុំមើលឯកសារសុខភាពរបស់អ្នក ហើយស្នើសុំផ្លាស់ប្តូរវា ប្រសិនបើវាមិនត្រឹមត្រូវ។ អ្នកក៏អាចស្នើសុំផងដែរដើម្បីឱ្យគេផ្ញើឯកសារសុខភាពរបស់អ្នក ទៅឱ្យស្ថាប័នផ្តល់សេវាសុខភាពផ្សេងទៀត។ ប្រសិនបើគេបដិសេធសំណើទាំងនេះ អ្នកសមនឹងទទួលបាន ការពន្យល់ជាលាយលក្ខណ៍អក្សរ។



សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញសំណុំបែបបទពាក្យបណ្តឹងតាមអនឡាញ សូមបើកចូលវ៉ិបសាយ **hcc.vic.gov.au**

ទូរស័ព្ទ **1300 582 113** រវាងម៉ោង៩ព្រឹក និងម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ដើម្បីពិភាក្សាអំពីពាក្យបណ្តឹងរបស់អ្នក។

HEALTH COMPLAINTS COMMISSIONER



HEALTH COMPLAINTS COMMISSIONER

# ឯកសារសុខភាពរបស់ខ្ញុំ សិទ្ធិរបស់ខ្ញុំ

Khmer | ភាសាខ្មែរ

គាំទ្រការថែទាំសុខភាពដែលមានសុវត្ថិភាព និងត្រឹមត្រូវតាមសីលធម៌



## តើនរណាកាន់កាប់ព័ត៌មានសុខភាពរបស់ខ្ញុំ?

ស្ថាប័នផ្តល់សេវាសុខភាពទាំងឡាយ ដូចជាមន្ទីរពេទ្យ និងគ្រូពេទ្យធ្មេញ ព្រមទាំងស្ថាប័នផ្តល់សេវាមិនមែនផ្នែកសុខភាព ដូចជាសាលារៀន ក្រុមហ៊ុនធានារ៉ាប់រង និងទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់ដែលប្រមូលព័ត៌មានសុខភាព។ ពួកគេអាចកាន់កាប់ប្រវត្តិវេជ្ជសាស្ត្ររបស់អ្នក លទ្ធផលការធ្វើតេស្ត សំបុត្រពេទ្យឈប់សម្រាកពីការឈឺ បញ្ជីថ្នាំព្យាបាល និងព័ត៌មានជាច្រើនទៀត។ ប្រសិនបើពួកគេបង្កើតជាកំណត់ត្រា មានន័យថា ពួកគេជាម្ចាស់កម្មសិទ្ធកំណត់ត្រានេះ។

## តើពួកគេមានកាតព្វកិច្ចអ្វីខ្លះ?

ព័ត៌មានសុខភាព គួរត្រូវបានគេប្រមូលដោយមានការយល់ព្រមរបស់អ្នក ហើយត្រូវបានប្រើសម្រាប់គោលបំណងដែលគេប្រមូលយកតែប៉ុណ្ណោះ។ ដើម្បីប្រើប្រាស់វាសម្រាប់គោលបំណងដែលមិនទាក់ទងណាមួយ ពួកគេត្រូវការការអនុញ្ញាតរបស់អ្នក។

ព័ត៌មានរបស់ពួកគេគួរមានភាពត្រឹមត្រូវ ទាន់បច្ចុប្បន្នភាព ហើយនិងពាក់ព័ន្ធទៅនឹងកិច្ចការរបស់ពួកអ្នកដែលប្រមូលវា។ ពួកគេត្រូវរក្សាទុក ផ្ទេរ និងបោះចោលព័ត៌មានដោយសុវត្ថិភាព ដើម្បីការពារភាពឯកជនរបស់អ្នក។ ប្រសិនបើស្ថាប័នរបស់អ្នកផ្លាស់ប្តូរទីបរិវេណ ឬបិទកន្លែងធ្វើការ ពួកគេគួរតែកាសជូនដំណឹងជាសាធារណៈ។

## តើខ្ញុំអាចបើកចូលកំណត់ត្រារបស់ខ្ញុំដោយរបៀបណា?

ជំហានដំបូង គឺត្រូវទាក់ទងជាមួយអស់អ្នកដែលកាន់កាប់ឯកសារសុខភាពរបស់អ្នក។ ប្រសិនបើអ្នកមិនពេញចិត្តនឹងការឆ្លើយតបរបស់ពួកគេទេ អ្នកអាចដាក់ពាក្យបណ្តឹង។

Health Complaints Commissioner (ស្នងការទទួលពាក្យបណ្តឹងផ្នែកសុខភាព) ដោះស្រាយពាក្យបណ្តឹងអំពីស្ថាប័នថែទាំសុខភាព និងអំពីអង្គការឯកជនណាមួយ ដែលកាន់កាប់ព័ត៌មានសុខភាពក្នុងរដ្ឋវិចតូរីយ៉ា។

ការប្តឹងតវ៉ាអំពីការកាន់កាប់នៃឯកសារសុខភាពរបស់អ្នក ដោយអង្គការសាធារណៈ សូមទាក់ទងមកស្នងការទទួលបន្ទុកសេរីភាពដើម្បីទទួលបានព័ត៌មាន។

ការិយាល័យយើងខ្ញុំអាចជួយអ្នកដើម្បីបើកចូល ឬកែតម្រូវកំណត់ត្រារបស់អ្នក ទទួលបានការពន្យល់ ការសុំអភ័យទោស និងការទទួលប្រាក់សងមកវិញ ឬសូម្បីតែការផ្លាស់ប្តូររបៀបដែលសេវាណាមួយចាត់ចែងព័ត៌មានសុខភាព។

សេវាកម្មរបស់យើងខ្ញុំផ្តល់ជូនដោយឥតគិតថ្លៃ រក្សាការសម្ងាត់ ហើយមិនលំអៀង។

### ទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញសំណុំបែបបទពាក្យបណ្តឹងតាមអនឡាញ សូមបើកចូលវ៉ិបសាយ **hcc.vic.gov.au**

ទូរស័ព្ទ **1300 582 113** រវាងម៉ោង៩ព្រឹក និងម៉ោង៥ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ដើម្បីពិភាក្សាអំពីពាក្យបណ្តឹងរបស់អ្នក។

សូមអញ្ជើញមក ឬសរសេរមកយើងខ្ញុំនៅអាសយដ្ឋាន
Level 26, 570 Bourke Street, Melbourne Victoria 3000

តើថ្លង់ ពិបាកស្តាប់ ឬអន់ខ្សោយក្នុងការនិយាយស្តីឬ?
**relayservice.gov.au**

តើត្រូវការអ្នកបកប្រែភាសាឬទេ?
TIS National: **131 450**

នេះគឺជាព័ត៌មានដែលមានលក្ខណៈទូទៅ ហើយមិនមានបំណងជាការផ្តល់ដំបូន្មានផ្នែកច្បាប់ឡើយ